**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ៧៤៧ ពណ.សជ

ថ្ងៃសុក្រ ១១កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពីការដាក់ឲ្យអនុវត្តសាកល្បងមុខងារស្នើសុំ អាជ្ញាប័ណ្ណនាំចេញ-នាំចូល និងវិញ្ញាបនបត្រត្បូងពេជ្រមិនទាន់កែច្នៃតាមរយៈប្រព័ន្ធបញ្ជរតែមួយជាតិ

យោងតាមប្រកាសលេខ ៥៧៥ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឲ្យអនុវត្តជំហានដំបូងប្រព័ន្ធបញ្ជរតែមួយជាតិ ដែលបានកំណត់នីតិវិធីនៃការស្នើសុំ និងការចេញអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតតាមប្រព័ន្ធបញ្ជរតែមួយជាតិ សម្រាប់បម្រើឲ្យប្រតិបត្តិការនាំចេញ-នាំចូល និងឆ្លងកាត់ទំនិញ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណៈជនទាំងអស់ឲ្យបានជ្រាបថា៖ លោក លោកស្រី អ្នកនាង កញ្ញា ដែលជាម្ចាស់ទំនិញ ឬតំណាងដែលទទួលបានការអនុញ្ញាតឲ្យបំពេញបែបបទក្នុងនាមម្ចាស់ទំនិញ អាចចុះឈ្មោះសុំគណនីប្រើប្រាស់ប្រព័ន្ធ ព្រមទាំងអាចស្នើសុំអាជ្ញាប័ណ្ណនាំចេញ-នាំចូល និងវិញ្ញាបនបត្រត្បូងពេជ្រមិនទាន់កែច្នៃ នៃគម្រោងចេញវិញ្ញាបនបត្រគីមប៊ើលីប្រូសេស តាមរយៈគេហទំព័រ "www.nsw.gov.kh" ដោយត្រូវបំពេញបែបបទក្នុងប្រព័ន្ធ រួចភ្ជាប់ជាមួយនូវឯកសារគាំទ្រនានាក្នុងទម្រង់អេឡិចត្រូនិក តាមបទបញ្ញត្តិជាធរមាន ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ នេះតទៅ។

ចំពោះព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

១-លោក ស៊ី បាទិត្យ អនុប្រធាននាយកដ្ឋាននាំចេញ-នាំចូល ក្រសួងពាណិជ្ជកម្ម

ទូរស័ព្ទ: ០១២ ៩៤៨ ៤៨៤ សារអេឡិចត្រូនិក: batithsy@yahoo.com

២-លោក អឿន សុភាព ប្រធានការិយាល័យ នៃនាយកដ្ឋាននាំចេញ-នាំចូល ក្រសួងពាណិជ្ជកម្ម

ទូរស័ព្ទ: ០១២ ៨៧៦ ៩៦៧ សារអេឡិចត្រូនិក: sopheap.oeun@gmail.com

៣-លោក ញ គី ប្រធានការិយាល័យ នៃនាយកដ្ឋាននាំចេញ-នាំចូល ក្រសួងពាណិជ្ជកម្ម

ទូរស័ព្ទ: ០១២ ៨៧៧ ៧១២ សារអេឡិចត្រូនិក: nhokey12@gmail.com

៤-លោក សោម សុទ្ធា មន្ត្រី នៃនាយកដ្ឋាននាំចេញ-នាំចូល ក្រសួងពាណិជ្ជកម្ម

ទូរស័ព្ទ: ០៧០ ៦០៦ ០០៤ សារអេឡិចត្រូនិក: somsothea@gmail.com

អាស្រ័យដូចបានជូនដំណឹងខាងលើ សូមសាធារណៈជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឲ្យមានប្រសិទ្ធិភាព។

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងពាណិជ្ជកម្ម *

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469